**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-Sep-2011, 15:10
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ៖ សហព្រះរាជអាជ្ញា

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬអង្គជំនុំជម្រះ ៖ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

# សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំរបាយការណ៍ស្តីពី អៀង ធីរិទ្ធ ដែលត្រូវរៀបចំឡើងដោយមន្ទីរឃុំឃាំង អ.វ.ត.ក

---

**ដាក់ដោយ៖**

សហព្រះរាជអាជ្ញា
ជា លាង
Andrew CAYLEY

**ផ្ញើជូន៖**

អង្គជំនុំជម្រះសាលាដំបូង
ចៅក្រម **និល ណុន** ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **យូ ឧត្តរា**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ
Ms. Elisabeth SIMONNEAU FORT

**ចម្លងជូន៖**

ជនជាប់ចោទ
អៀង ធីរិទ្ធ

**សហមេធាវីការពារក្តី៖**

ផាត់ ពៅស៊ាង
Diana ELLIS

## I. សេចក្តីផ្តើម និង ប្រវត្តិនីតិវិធី

១ សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យប្រធានមន្ទីរឃុំឃាំង និងមន្ត្រីអន្តរជាតិនៃអង្គភាពទំនាក់ទំនងមន្ទីរឃុំឃាំង អ.វ.ត.ក ដាក់របាយការណ៍ពិស្តារ ស្តីពីសកម្មភាព និងឥរិយាបថ របស់ អៀង ធីរិទ្ធ នៅមន្ទីរឃុំឃាំង អ.វ.ត.ក ដែលរៀបចំដោយប្រធានមន្ទីរឃុំឃាំង និងមន្ត្រីអន្តរជាតិនៃអង្គភាពទំនាក់ទំនងមន្ទីរឃុំឃាំង។

២ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១ លោក Claude BOUCHARD មន្ត្រីអន្តរជាតិនៃអង្គភាពទំនាក់ទំនងមន្ទីរឃុំឃាំង បានរៀបចំអនុស្សរណៈមួយ ដើម្បីឆ្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ស្នើសុំរបាយការណ៍មួយដែលមានព័ត៌មាន ឬការកត់សម្គាល់បន្ថែម ដែលចាត់ទុកថាពាក់ព័ន្ធទៅនឹងសុខភាពផ្លូវកាយ ឬសុខភាពផ្លូវចិត្តរបស់ជនជាប់ចោទទាំងបួនរូប ក្នុងសំណុំរឿង ០០២[១]។ អនុស្សរណៈរបស់លោក BOUCHARD បានពិពណ៌នាអំពីបរិយាកាសទូទៅ នៅក្នុងមន្ទីរឃុំឃាំង និងមតិសង្ខេបៗស្តីពីរបៀបដែលជនជាប់ចោទសម្របខ្លួនទៅនឹងលក្ខខណ្ឌនៃការឃុំខ្លួន។

៣ នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាចាត់តាំងអ្នកជំនាញ ដោយបង្គាប់ឱ្យសាស្ត្រាចារ្យ John CAMPBELL ជាគ្រូពេទ្យផ្នែកព្យាបាលមនុស្សចាស់ ពិនិត្យ អៀង ធីរិទ្ធ និងផ្តល់របាយការណ៍ស្តីពីសតិបញ្ញា និងកាយសម្បទារបស់គាត់ ដើម្បីអាចឱ្យអង្គជំនុំជម្រះវាយតម្លៃថាតើគាត់មានសម្បទាអាចចូលរួមក្នុងសវនាការបានដែរ ឬយ៉ាងដូចម្តេច[២]។ សាស្ត្រាចារ្យ CAMPBELL បានសន្និដ្ឋាននៅក្នុងរបាយការណ៍ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ របស់គាត់[៣] ថា អៀង ធីរិទ្ធ មាន"ជំងឺវង្វេងស្មារតីធ្ងន់ធ្ងរកម្រិតមធ្យម" ដែលក្រោយមកគាត់បានបញ្ជាក់ថា វាជាជំងឺចុះខ្សោយសតិបញ្ញាកម្រិត"មធ្យម"[៤]។ គាត់បានសន្និដ្ឋានថា ជំងឺចុះខ្សោយសតិបញ្ញានេះ នឹងប៉ះពាល់ដល់លទ្ធភាពចូលរួមឱ្យបានពេញលេញនៅក្នុងការជំនុំជម្រះក្តី និងការ

---

[១] **E31/1** អនុស្សរណៈអន្តរការិយាល័យ ពីលោក Claude BOUCHARD ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១១

[២] **E62/3** ដីកាចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១១

[៣] **E62/3/6** របាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់--លោកស្រី អៀង ធីរិទ្ធ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១

[៤] **E1/9.1** ប្រតិចារិកនៃសវនាការថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ត្រង់ទំព័រទី ៣៧។

អនុវត្តសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់គាត់[៥]។ គាត់បានកត់សម្គាល់ថា ការបញ្ឈប់ការប្រើប្រាស់ឱសថសម្រួលស្ថានភាពផ្លូវចិត្ត អាចធ្វើឲ្យមុខងារសតិបញ្ញារបស់គាត់ មានភាពប្រសើរឡើងវិញ និងគាត់បានផ្តល់ជាអនុសាសន៍ថា កម្រិតឱសថដែលប្រើប្រាស់គប្បីកាត់ បន្ថយបន្តិចម្តងៗ រហូតឈានដល់បញ្ឈប់ទាំងស្រុង[៦]។

៤ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១ សាស្ត្រាចារ្យ CAMPBELL បានដាក់របាយការណ៍ពិនិត្យ និង វាយតម្លៃបន្ថែមលើរូប អៀង ធីរិទ្ធ ក្រោយពីការចាប់ផ្តើមបន្ថយការប្រើប្រាស់ឱសថសម្រួល ស្ថានភាពផ្លូវចិត្តរបស់គាត់[៧]។ គាត់បានរកឃើញថាមុខងារសតិបញ្ញាពុំមានភាពប្រសើរឡើងនោះ ទេ ប៉ុន្តែគាត់បានផ្តល់អនុសាសន៍ដល់អង្គជំនុំជម្រះសាលាដំបូងឲ្យសាកល្បងឱសថ acetylcholinesterase ដែលគាត់គិតថា "អាចផ្តល់លទ្ធភាពឲ្យគាត់អាចចូលរួមក្នុងការការពារក្តីរបស់គាត់ បានប្រសើរជាងមុន"[៨]។

៥ សាស្ត្រាចារ្យ CAMPBELL បានផ្តល់ភ័ស្តុតាងបន្ថែមពាក់ព័ន្ធនឹងការរកឃើញរបស់គាត់ នៅក្នុង សវនាការបឋមស្តីពីសម្បទាដើម្បីចូលរួមក្នុងសវនាការ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៩ ដល់ ៣១ ខែសីហា ឆ្នាំ២០១១។ នៅក្នុងសវនាការទាំងនេះ គាត់បានបញ្ជាក់អំពីការរកឃើញរបស់គាត់នៅ ក្នុងរបាយការណ៍ខាងលើ ប៉ុន្តែគាត់បានផ្តល់សក្ខីកម្មផងដែរថា បើគេមិនទាន់ប្រើប្រាស់ឲ្យអស់ វិធានការដើម្បីធ្វើឲ្យមុខងារសតិបញ្ញារបស់ អៀង ធីរិទ្ធ មានភាពប្រសើរឡើងនៅឡើយនោះទេ គេមិនអាចសន្និដ្ឋានបានថាគាត់នឹងគ្មានលទ្ធភាពចូលរួមក្នុងការការពារក្តីរបស់គាត់បាននោះទេ[៩]។

---

[៥] **E62/3/6** របាយការណ៍អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់--លោកស្រី អៀង ធីរិទ្ធ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ៤០ និង ៤១។

[៦] ដូចខាងលើ កថាខណ្ឌ ៤២

[៧] **E62/3/12** របាយការណ៍ពិនិត្យនិងវាយតម្លៃបន្ថែមពាក់ព័ន្ធនឹងលោកស្រី អៀង ធីរិទ្ធ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១ អនុលោមតាមដីកាចាត់តាំងអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូងលេខ E62/3 ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១១។

[៨] **E62/3/12** របាយការណ៍ពិនិត្យនិងវាយតម្លៃបន្ថែមពាក់ព័ន្ធនឹងលោកស្រី អៀង ធីរិទ្ធ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១ អនុលោមតាមដីកាចាត់តាំងអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូងលេខ E62/3 ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១១។

[៩] **E1/9.1** ប្រតិចារិកនៃសវនាការថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ទំព័រទី ៩២។

៦ នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចាត់តាំងអ្នកជំនាញបួនរូបបន្ថែម ដើម្បីវាយតម្លៃសមត្ថភាពផ្លូវចិត្ត និងសតិបញ្ញារបស់ អៀង ធីរិទ្ធ[១០]។

## III. ច្បាប់ជាធរមាន

៧ ទោះបីជាទស្សនៈរបស់អ្នកជំនាញ ផ្តល់ការយល់ដឹងដ៏មានតម្លៃដល់អង្គជំនុំជម្រះសាលាដំបូងអំពីស្ថានភាពសម្បទាផ្លូវកាយ និងសតិបញ្ញារបស់ជនជាប់ចោទយ៉ាងណាក្តី ក៏ទាំងនេះគឺគ្រាន់តែជាកត្តាមួយក្នុងចំណោមកត្តាជាច្រើនទៀត ដែលអង្គជំនុំជម្រះអាចយកមកធ្វើជាសំអាង នៅពេលធ្វើសេចក្តីសម្រេចថាតើជនជាប់ចោទមានសម្បទា ដើម្បីចូលរួមក្នុងសវនាការបាន ឬយ៉ាងដូចម្តេចតែប៉ុណ្ណោះ។ ចៅក្រមមួយរូបនៃក្រុមប្រឹក្សាជំនុំជម្រះពិសេសសម្រាប់បទឧក្រិដ្ឋកម្រិតធ្ងន់នៅប្រទេសទីម័រខាងកើត បានកត់សម្គាល់នៅក្នុងករណី *Nahak* ថាតុលាការ "ពុំជាប់កាតព្វកិច្ចត្រូវតែគោរពតាមទស្សនៈរបស់អ្នកជំនាញណាមួយពាក់ព័ន្ធនឹងសមត្ថភាពនោះទេ... ដ្បិតសេចក្តីសម្រេចពាក់ព័ន្ធនឹងសមត្ថភាពនេះ គឺជាសេចក្តីសម្រេចតាមផ្លូវតុលាការ មិនមែនសេចក្តីសម្រេចខាងវិទ្យាសាស្ត្រនោះទេ"[១១]។ កត្តាបន្ថែមផ្សេងទៀត ដែលតុលាការអាចយកមកពិចារណា រួមមានការកត់សម្គាល់ផ្ទាល់ខ្លួនរបស់ចៅក្រម ការប្រាស្រ័យទាក់ទងគ្នារវាងជនជាប់ចោទ និងមេធាវីការពារក្តីរបស់គាត់ និងសក្ខីកម្មនៃជនសាមញ្ញដែលបានដឹងឮអំពីការប្រព្រឹត្តិប្រចាំថ្ងៃ និងស្ថានភាពផ្លូវចិត្តរបស់អ្នកជាប់ឃុំ[១២]។

៨ ក្នុងករណី *Kovacevic* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានបង្គាប់ឲ្យមន្ត្រីទទួលបន្ទុកអង្គភាពមន្ទីរឃុំឃាំងនៃអង្គការសហប្រជាជាតិ ដាក់របាយការណ៍ស្តីពីការកត់សម្គាល់របស់គាត់ និងបុគ្គលិករបស់គាត់ ពាក់ព័ន្ធនឹងសកម្មភាពរបស់ជនជាប់ចោទ នៅក្នុងអង្គភាពមន្ទីរ

---

[១០] E111 ដីកាចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១១។

[១១] *អគ្គរដ្ឋអាជ្ញារងសម្រាប់បទឧក្រិដ្ឋកម្រិតធ្ងន់ ទល់នឹង Joseph Nahak*, សំណុំរឿងលេខ 01A/2004, ការរកឃើញ និងដីកាស្តីពីសមត្ថភាពរបស់ជនជាប់ចោទ Nahak ក្នុងការចូលរួមក្នុងសវនាការ (ក្រុមប្រឹក្សាជំនុំជម្រះពិសេសសម្រាប់បទឧក្រិដ្ឋ កម្រិតធ្ងន់ (Timor-Leste)) ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០០៥ ត្រង់កថាខណ្ឌ ១២០។

[១២] ដូចខាងលើ

ឃុំឃាំងនៃអង្គការសហប្រជាជាតិ[១៣]។ ក្រោយមក អង្គជំនុំជម្រះបានកោះហៅមន្ត្រីទទួលបន្ទុករូបនោះ ដើម្បីមកធ្វើសក្ខីកម្មពាក់ព័ន្ធនឹងការកត់សម្គាល់ផ្ទាល់ខ្លួនរបស់គាត់ អំពីឥរិយាបថរបស់ជនជាប់ចោទនៅក្នុងមន្ទីរឃុំឃាំង[១៤]។

## III- ឧទ្ធរណ៍

៩ ដោយសារតែភាពស្មុគស្មាញនៃស្ថានភាពពិតប្រាកដរបស់ អៀង ធីរិទ្ធ និងភាពខុសគ្នានៅក្នុងការវាយតម្លៃផ្នែកវេជ្ជសាស្ត្រ ដែលបានធ្វើឡើងក្នុងរយៈពេលពីរឆ្នាំកន្លងមក[១៥] ជាការសមស្រប គេគប្បីរៀបចំឱ្យមានការសាកសួរលម្អិតមួយ និងព្រមទទួលយកប្រភេទនៃព័ត៌មានដែលពាក់ព័ន្ធ និងដែលជឿទុកចិត្តបានបន្ថែមទៀត។ បើធ្វើដូច្នេះបានមែន គេប្រាកដជាជឿជាក់ថាអង្គជំនុំជម្រះអាចទទួលបានការយល់ដឹងដ៏សុក្រឹតបំផុតស្តីពីសមត្ថភាពរបស់ជនជាប់ចោទ។

១០ សហព្រះរាជអាជ្ញាយល់ឃើញថា គេគប្បីស្វះស្វែងរករបាយការណ៍លម្អិតមួយពីប្រធានមន្ទីរឃុំឃាំង អ.វ.ត.ក និងមន្ត្រីអន្តរជាតិនៃអង្គភាពទំនាក់ទំនងមន្ទីរឃុំឃាំង។ បុគ្គលទាំងនេះ រួមទាំងបុគ្គលិកមន្ទីរឃុំឃាំង គឺជាអ្នកដែលបានទាក់ទង អៀង ធីរិទ្ធ ដោយផ្ទាល់ និងខ្ជាប់ខ្ជួនចាប់តាំងពីពេលដែលគាត់ជាប់ឃុំឃាំងក្នុងខែវិច្ឆិកា ឆ្នាំ២០០៧។ ដោយសារតែបានប្រាស្រ័យទាក់ទងគ្នានឹង អៀង ធីរិទ្ធ ប្រចាំថ្ងៃក្នុងរយៈពេលនៃការឃុំខ្លួននេះ ពួកគេពិតជាអ្នកដែលអាចផ្តល់ការកត់សម្គាល់ក្នុងនាមជាជនសាមញ្ញស្តីអំពីឥរិយាបថទូទៅ និងការប្រព្រឹត្តិទម្លាប់ប្រចាំថ្ងៃរបស់គាត់ និងសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់គាត់នៅក្នុងមន្ទីរឃុំឃាំង។ ក្នុងនាមជាមន្ត្រីគ្រប់គ្រងមន្ទីរឃុំឃាំងដែលមានបទពិសោធន៍ ពួកគេក៏អាចផ្តល់យោបល់ពាក់ព័ន្ធការប្រែប្រួលណាមួយដែលកើតមានឡើងពាក់ព័ន្ធនឹងឥរិយាបថ និងស្ថានភាពសុខុមាលភាពទូទៅរបស់ អៀង ធីរិទ្ធ។ ចំណុចនេះមានភាពពាក់ព័ន្ធគ្នា ជាពិសេសទៅនឹងទស្សនៈរបស់ សាស្ត្រាចារ្យ CAMPBELL ដែលលោក

---

[១៣] *រដ្ឋអាជ្ញា ទល់នឹង Vladimir Kovačević*, សំណុំរឿងលេខ IT-01-42/2-I, សេចក្តីសម្រេចស្តីពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមដើម្បីតតាំងក្តី និងចូលរួមក្នុងសវនាការ (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៦ ត្រង់កថាខណ្ឌ ៩។

[១៤] ដូចខាងលើ ត្រង់កថាខណ្ឌ ១០។

[១៥] ចំណុចទាំងនេះមានសង្ខេបជូននៅត្រង់កថាខណ្ឌ ៥ និង ៦ នៃឯកសារ **E112** សំណួរ និងមតិរបស់សហព្រះរាជអាជ្ញាសម្រាប់អ្នកជំនាញផ្នែកចិត្តសាស្ត្រ ពាក់ព័ន្ធនឹងជនជាប់ចោទ អៀង ធីរិទ្ធ ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១១។

បានកត់សម្គាល់ថា មុខងារសតិបញ្ញារបស់ អៀង ធីរិទ្ធ មានភាពចុះខ្សោយច្រើន ចាប់តាំងពីខែតុលា ឆ្នាំ២០០៩[១៦] ។

១១ ជាការពិត របាយការណ៍អ្នកជំនាញ មានសារសំខាន់ដើម្បីបញ្ជាក់ឲ្យឃើញច្បាស់អំពីបញ្ហាមិនប្រក្រតីណាមួយនៃសតិបញ្ញារបស់ អៀង ធីរិទ្ធ។ ទោះជាយ៉ាងនេះក្តី ដោយសារតែសាវតារ និងភាពមិនច្បាស់លាស់នៃស្ថានភាពនៅចំពោះមុខនេះ ជាការចាំបាច់គេត្រូវតែធ្វើយ៉ាងណាប្រមូលឲ្យបានទូរវាល់ភ័ស្តុតាងដែលអាចរកបាន ដើម្បីយកមកដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ សាស្ត្រាចារ្យ CAMPBELL បានផ្តល់សក្ខីកម្មថា នៅពេលដែលគាត់សម្ភាស អៀង ធីរិទ្ធ ដោយរូបគាត់តែម្នាក់ឯង អៀង ធីរិទ្ធ ដឹងថាពេលនោះគឺជាស្ថានភាពធ្វើតេស្តមួយ និងថាប្រការនោះ “អាចមានផលប៉ះពាល់ដល់ការឆ្លើយតបរបស់ អៀង ធីរិទ្ធ”[១៧]។ គាត់បានពន្យល់ថា មាន“ការប្លែកគ្នាគួរឲ្យកត់សម្គាល់ចំពោះរបៀបដែល អៀង ធីរិទ្ធ សម្តែងឥរិយាបថ និងប្រាស្រ័យទាក់ទងគ្នានឹងអ្នកដែលសម្ភាសគាត់”[១៨] និង “មានពេលខ្លះ គាត់ចូលរួមជាមួយនឹងមនុស្សជាក់លាក់មួយចំនួនបានល្អជាងជាមួយមនុស្សមួយចំនួនផ្សេងទៀត”[១៩]។ ការកត់សម្គាល់របស់ប្រធានមន្ទីរឃុំឃាំង អ.វ.ត.ក និងរបស់មន្ត្រីអន្តរជាតិនៃអង្គភាពទំនាក់ទំនងមន្ទីរឃុំឃាំង អាចជួយបំភ្លឺឲ្យបានច្បាស់លើបញ្ហានេះ និងម្យ៉ាងទៀតវាអាចជាព័ត៌មានមានប្រយោជន៍បន្ថែមលើព័ត៌មាន ដែលអ្នកជំនាញបានផ្តល់ជូនរួចហើយ។

១២ ដើម្បីឈានដល់ការសម្រេចអំពីសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមក្នុងសវនាការ អង្គជំនុំជម្រះសាលាដំបូងនឹងពិចារណាដោយគ្មានមន្ទិលសង្ស័យ ក្នុងចំណោមកត្តាជាច្រើន ទៅលើការកត់សម្គាល់របស់ខ្លួនចំពោះជនជាប់ចោទ។ ទោះជាយ៉ាងណាក៏ដោយ ការកត់សម្គាល់ទាំងនេះមានកម្រិតចំពោះកាលៈទេសៈមួយចំនួន នៅពេលដែលជនជាប់ចោទចូលខ្លួនមកក្នុងបន្ទប់សវនាការ ដែលតាមពិតទៅ គឺជាបរិយាកាសខុសគ្នាទាំងស្រុង ពីអ្វីដែលជនជាប់ចោទបានទទួលបទពិសោធនៅក្នុងជីវិតប្រចាំថ្ងៃរបស់គាត់។ នៅក្នុងអំឡុងសវនាការ ជនជាប់ចោទកំពុងប្រឈមមុខនឹង

---

[១៦] **E1/9.1** ប្រតិចារិកនៃសវនាការថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ត្រង់ទំព័រទី ៧១។

[១៧] **E1/8.1** ប្រតិចារិកនៃសវនាការថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ត្រង់ទំព័រទី ១៣៦។

[១៨] **E1/9.1** ប្រតិចារិកនៃសវនាការថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១១ ត្រង់ទំព័រទី ៨៩។

[១៩] ដូចខាងលើ។

ក្រុមប្រឹក្សាជំនុំជម្រះ និងមេធាវីជាច្រើន រួមទាំងអ្នកមកចូលរួមស្ដាប់សវនាការចំនួន៥០០ (ប្រាំរយ)នាក់ នៅក្នុងសាលសវនាការ។ វាជាការសមហេតុផលក្នុងការសន្មតថា ការសង្កត់ធ្ងន់ទៅលើបែបបទដែលអាចផ្ដល់លទ្ធផលបែបនេះ អាចនាំឱ្យការប្រព្រឹត្តិ និងឥរិយាបថមានលក្ខណៈខុសគ្នាពីអ្វី ដែល អៀង ធីរិទ្ធ បានសម្ដែងឱ្យឃើញតាមធម្មតា។ ក្នុងន័យនេះដែរ ការចេញរបាយការណ៍ដោយមន្ទីរឃុំឃាំងនឹងជួយដល់ចៅក្រមយ៉ាងច្រើន ដើម្បីកំណត់ឱ្យបានច្បាស់លាស់អំពីឥរិយាបថ និងសកម្មភាពទូទៅរបស់ អៀង ធីរិទ្ធ។

## IV. **សំណួរ**

១៣ សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះបង្គាប់ដល់ប្រធានមន្ទីរឃុំឃាំង លោក ម៉ៅ សុភារម្យ និងមន្ត្រីអន្តរជាតិសម្របសម្រួលមន្ទីរឃុំឃាំង លោក Claude BOUCHARD ផ្ដល់ជូននូវរបាយការណ៍មួយដែលឆ្លើយទៅនឹងសំណួរទាំងឡាយដូចខាងក្រោម នៅក្នុងរយៈពេល ១៤ (ដប់បួន) ថ្ងៃ៖

### <u>ការប្រាស្រ័យទាក់ទងរបស់ អៀង ធីរិទ្ធ ជាមួយបុគ្គលិកមន្ទីរឃុំឃាំង អ.វ.ត.ក និងអ្នកដទៃទៀតនៅក្នុងមន្ទីរឃុំឃាំង</u>

ក) សូមរៀបរាប់អំពីការប្រាស្រ័យទាក់ទងរបស់ អៀង ធីរិទ្ធ ជាមួយលោកទាំងពីរ និងបុគ្គលិកមន្ទីរឃុំឃាំង៖ តើគាត់អាចចំណាំអ្នកដែលធ្វើការនៅក្នុងមន្ទីរឃុំឃាំងបានដែរ ឬទេ? តើគាត់ស្គាល់ឈ្មោះ និងតួនាទីរបស់ពួកគេដែរ ឬទេ ហើយថាតើគាត់នឹកឃើញពីការប្រាស្រ័យទាក់ទងមុនៗរបស់គាត់ជាមួយពួកគេដែរ ឬទេ?

ខ) តើលោកប្រាស្រ័យទាក់ទងជាមួយ អៀង ធីរិទ្ធ ញឹកញាប់ប៉ុន្មានដែរ? តើសម្ដីរបស់គាត់ស៊ីសង្វាក់គ្នា និងសមហេតុផលដែរ ឬទេ? តើគាត់ពិភាក្សាបញ្ហាដែលជាប់ទាក់ទងនឹងប្រធានបទនៃការសន្ទនានេះដែរ ឬទេ?

គ) តើ អៀង ធីរិទ្ធ បានធ្វើសំណើផ្សេងៗដល់បុគ្គលិកមន្ទីរឃុំឃាំងដែរ ឬទេ? តើសំណើទាំងនោះសមហេតុសមផលដែរ ឬទេ?

ឃ) តើគាត់យល់ និងធ្វើតាមការណែនាំទាំងឡាយ ដែលបានដាក់ជូនគាត់ដែរ ឬទេ?

ង) តើលោកបានធ្វើការកត់សម្គាល់អំពីការប្រែប្រួលណាមួយ នៅក្នុងការប្រាស្រ័យទាក់ទងរបស់

អៀង ធីរិទ្ធ ជាមួយបុគ្គលិកមន្ទីរឃុំឃាំងដែរ ឬទេ ជាពិសេស ចាប់តាំងពីពេលឃុំខ្លួនគាត់មក? ប្រសិនបើមានការប្រែប្រួលមែន សូមរៀបរាប់។

ច) តើមានភាពខុសគ្នាណាមួយនៅក្នុងការប្រាស្រ័យទាក់ទងរបស់ អៀង ធីរិទ្ធ ជាមួយនឹងមន្ត្រីអន្តរជាតិសម្របសម្រួលមន្ទីរឃុំឃាំងដែរ ឬទេ បើប្រៀបធៀបការប្រាស្រ័យទាក់ទងរបស់គាត់ជាមួយអ្នកដទៃ? ប្រសិនបើមានការប្រែប្រួលមែន សូមរៀបរាប់អំពីការប្រែប្រួលណាមួយនៅក្នុងការប្រាស្រ័យទាក់ទងទាំងនេះ។

ឆ) តើភាសាអ្វីដែលមន្ត្រីអន្តរជាតិសម្របសម្រួលមន្ទីរឃុំឃាំង បានប្រើប្រាស់ដើម្បីប្រាស្រ័យទាក់ទងជាមួយ អៀង ធីរិទ្ធ? ប្រសិនបើប្រើភាសាបរទេសណាមួយ តើលោកអាចវាយតម្លៃអំពីសមត្ថភាពរបស់ អៀង ធីរិទ្ធ ក្នុងការប្រាស្រ័យទាក់ទងជាភាសានោះបានដោយរបៀបណាដែរ? តើលោកបានធ្វើការកត់សម្គាល់ការចុះខ្សោយណាមួយ ចំពោះចំណេះដឹងរបស់គាត់ទៅលើភាសានោះដែរ ឬទេ?

ជ) ចាប់តាំងពីការមកដល់របស់ អៀង ធីរិទ្ធ នៅក្នុងមន្ទីរឃុំឃាំងនេះ តើលំហូរនៃការសន្ទនាបានចុះខ្សោយតាមមធ្យោបាយណាមួយដែរ ឬទេ? តើគាត់និយាយតិចជាងមុនដែរ ឬអត់?

ឈ) តើ អៀង ធីរិទ្ធ បានធ្វើការសន្ទនាជាមួយជនជាប់ចោទដទៃទៀតដែរ ឬទេ? តើការសន្ទនាទាំងនេះញឹកញាប់ និងមានរយៈពេលយូរប៉ុណ្ណាដែរ (កំណត់សម្គាល់៖ សូមកុំផ្តល់មតិយោបល់ទៅលើប្រធានបទនៃការសន្ទនាទាំងនេះ)?

**<u>ការបន្សាំខ្លួនទៅនឹងទីកន្លែង និងការយល់ដឹងជាទូទៅរបស់ អៀង ធីរិទ្ធ</u>**

ញ) តើ អៀង ធីរិទ្ធ ដឹងថាគាត់ត្រូវបានឃុំខ្លួន និងឃុំខ្លួននៅទីណាទេ?

ដ) តើគាត់ដឹងថា គាត់ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋជាក់លាក់មួយចំនួន និងអាចប្រឈមមុខទៅនឹងការជំនុំជម្រះនៅចំពោះមុខ អ.វ.ត.ក ដែរ ឬទេ?

ឋ) តើគាត់នៅចាំអំពីតួនាទីរបស់គាត់ជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច នៅក្នុងអំឡុងពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ ដែរ ឬទេ?

ឌ) ប្រសិនបើបាននិយាយគ្នាអំពីព្រឹត្តិការណ៍កាលពីអតីតកាល តាមការយល់ដឹងដ៏ត្រឹមត្រូវរបស់លោក តើការរៀបរាប់របស់គាត់អំពីព្រឹត្តិការណ៍ទាំងនោះត្រឹមត្រូវដែរ ឬទេ (ឧទាហរណ៍ ការចាប់ខ្លួនគាត់ និងការមកដល់មន្ទីរឃុំឃាំង)?

ឍ) តើគាត់ចាំកាលបរិច្ឆេទសំខាន់ៗ ដូចជា ថ្ងៃកំណើតរបស់គាត់ និងថ្ងៃឈប់សម្រាកសាធារណៈ

ដែរឬទេ?

ណ) តើគាត់ចាំកាលបរិច្ឆេទកំណត់ដោយតុលាការ ឬការណាត់ជួបផ្សេងៗដែរ ឬទេ?

ត) តើគាត់នៅមានការផ្តោតការយកចិត្តទុកដាក់ ឬក៏គាត់បាត់បង់អារម្មណ៍នៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក?

ថ) តើគាត់អាចប្រើប្រាស់នាឡិកាដៃ ឬនាឡិកាប៉ោលបានដែរ ឬទេ? តើគាត់ដឹងពីកាលបរិច្ឆេទ និងពេលវេលាដែរ ឬទេ?

ទ) តើគាត់មានទស្សនាទូរទស្សន៍ ឬអានសារព័ត៌មានដែរ ឬទេ?

ធ) តើគាត់ដឹងអំពីព្រឹត្តិការណ៍នានា ដែលជាចំណាប់អារម្មណ៍របស់សាធារណជនដែរ ឬទេ ដូចជា ព្រឹត្តិការណ៍ដែលត្រូវបានយកមកពិភាក្សានៅក្នុងប្រព័ន្ធផ្សព្វផ្សាយជាដើម?

ន) តើគាត់មានសរសេរឯកសារណាមួយ ដូចជា លិខិតឆ្លើយឆ្លង ឬកំណត់ត្រាខ្លីៗ (កំណត់ចំណាំ៖ សូមកុំផ្តល់មតិយោបល់ទៅលើខ្លឹមសារនៃឯកសារទាំងនេះឲ្យសោះ)?

## ការប្រាស្រ័យទាក់ទងរបស់ អៀង ធីរិទ្ធ ជាមួយភ្ញៀវទាំងឡាយ នៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក

ប) តើ អៀង ធីរិទ្ធ នៅចាំសមាជិកគ្រួសាររបស់គាត់ និងចាំឈ្មោះរបស់ពួកគេដែរ ឬទេ?

ផ) តើគាត់ចាំអ្នកមកសួរសុខទុក្ខគាត់ជាទូទៅដែរ ឬទេ? រួមទាំងសមាជិកក្រុមការពារក្តី?

ព) តើគាត់យល់ពីវិធានគ្រប់គ្រងពន្ធនាគារ និងចាំពេលវេលានៃការមកសួរសុខទុក្ខដែរ ឬទេ?

ភ) តើគាត់មានធ្វើសំណូមពរណាមួយទាក់ទងនឹងការមកសួរសុខទុក្ខទាំងនេះដែរ ឬទេ?

ម) តើគាត់ជួបសមាជិកក្រុមអ្នកការពារក្តីញឹកញាប់ដែរ ឬទេ?

យ) តើការជួបជាមួយសមាជិកក្រុមមេធាវីការពារក្តី ជាទូទៅមានរយៈពេលប៉ុន្មាន?

## V. សេចក្តីសន្និដ្ឋាន

១៤ សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង៖

ក) បង្គាប់ឲ្យលោក សុភារម្យ និងលោក BOUCHARD ផ្តល់របាយការណ៍រួមគ្នាមួយ ដោយ

ធ្វើការបញ្ជាក់លម្អិតអំពីសំណួរដែលបានលើកឡើងខាងលើ។

ខ) ផ្តល់របាយការណ៍នេះមួយច្បាប់ជូនភាគីនានា និងគ្រូពេទ្យផ្នែកវិកលចរិត ដែលត្រូវបានចាត់តាំងកាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១ និង

គ) កោះអញ្ជើញលោក ម៉ៅ សុភារម្យ និងលោក BOUCHARD ឱ្យមកផ្តល់សក្ខីកម្មស្តីពីការកត់សម្គាល់របស់ខ្លួន នៅក្នុងសវនាការណាមួយនាពេលខាងមុខ ស្តីពីសម្បទារបស់ អៀង ធីរិទ្ធ ដើម្បីចូលរួមក្នុងសវនាការ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១ | លោកស្រី **ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | លោក Andrew Cayley<br>សហព្រះរាជអាជ្ញា | | [signature] |